អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# សេចក្តីប្រកាសព័ត៌មាន

លោក **ខៀវ សំផន** ត្រូវបាននាំខ្លួនមកមន្ទីរឃុំឃាំងរបស់អង្គជំនុំជម្រះវិសាមញ្ញ នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ ២០០៧ ។ អង្គភាពគាំពារការការពារក្តីបានចាត់តាំងមេធាវីពីររូបដែលជ្រើសរើសដោយលោក **ខៀវ សំផន** ចេញពីបញ្ជីមេធាវីរបស់អង្គជំនុំជម្រះវិសាមញ្ញ ។មេធាវីទាំងពីររូបនេះ មានលោកបណ្ឌិត **សាយ បូរី** សមាជិកគណៈមេធាវីកម្ពុជានៃព្រះរាជាណាចក្រកម្ពុជា និងលោក **Jacques VERGÈS** មកពីគណៈមេធាវីទីក្រុងបារីស ។

លោកបណ្ឌិត **សាយ បូរី** ជាសមាជិកជាន់ខ្ពស់នៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ហើយក៏ជាប្រធានទី១នៃគណៈមេធាវីនេះផងដែរ ដែលបង្កើតឡើងនៅឆ្នាំ ១៩៩៥ ។ លោកមេធាវី **សាយ បូរី** ជាសមាជិកនៃក្រុមប្រឹក្សាធម្មនុញ្ញពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០៤ ហើយក្រោយមកគាត់ក៏ប្រកបវិជ្ជាជីវៈឯកជន ។ លោកបណ្ឌិត **សាយ បូរី** ជាទីប្រឹក្សាផ្នែកច្បាប់អតីតព្រះមហាក្សត្រ **ព្រះបាទសម្តេចព្រះនរោត្តមសីហនុ** ។

លោក **Jacques VERGÈS** ជាសមាជិកនៃគណៈមេធាវីទីក្រុងបារីស ចាប់តាំងពីឆ្នាំ ១៩៥៥ ។ នៅទសវត្សរ៍ឆ្នាំ ១៩៦០ គាត់បានការពាររឿងក្តីជាច្រើននៅតុលាការយោធាបារាំង ដែលកើតឡើងដោយសារជម្លោះនៅអាល់ហ្សេរី ។ នៅឆ្នាំ១៩៨៧ គាត់ការពាររឿងក្តី Klaus Barbie នៅតុលាការព្រហ្មទណ្ឌលីយ៉ុង [Lyon cour d'assises] ដែលត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រព្រឹត្តកាលពីអំឡុងសង្គ្រាមលោកលើកទី២ ។ លោក **VERGÈS** បានការពារកូនក្តីសំខាន់ៗជាច្រើននៅតុលាការជាតិ និងតុលាការអន្តរជាតិ ។

សហមេធាវីទាំងពីរត្រូវចាត់តាំងជាបណ្តោះអាសន្ន ស្របពេលដែលអង្គភាពគាំពារការការពារក្តីវាយតំលៃថាតើលោក **ខៀវ សំផន** មានមធ្យោបាយហិរញ្ញវត្ថុគ្រប់គ្រាន់ ដើម្បីបង់ថ្លៃសេវាក្រុមការពារក្តីរបស់គាត់សំរាប់រយៈពេលពីរឆ្នាំខាងមុខ ។

ECCC, National Road 4, Chaom Chau, Dangkao, PO Box 71, Phnom Penh, Cambodia
Tel: +(855) 023 219 814 Fx: +(855) 023 219 841 Web: www.eccc.gov.kh